

# កិច្ចបំរើថែទាំនៅតាមផ្ទះនិងក្នុងសហគមន៍ (កិច្ចបំរើ HACC)

ជួយលោកអ្នកនៅផ្ទះ និងនៅក្នុងសហគមន៍របស់លោកអ្នក

hacc
home and community care
A JOINT COMMONWEALTH AND STATE/TERRITORY PROGRAM PROVIDING FUNDING AND ASSISTANCE FOR AUSTRALIANS IN NEED

## តើអ្វីទៅជាកម្មវិធីកិច្ចបំរើ HACC?

មនុស្សភាគច្រើនចង់រស់នៅផ្ទះរបស់គេ ប៉ុន្តែមនុស្សវ័យចាស់ទន់ខ្សោយ និងមនុស្សមានពិការភាពមួយចំនួនមានការពិបាកក្នុងការ រស់នៅផ្ទះដោយគ្មានជំនួយ ។ ជំនួយអាចផ្តល់ដោយអ្នកមើលថែ (សមាជិកគ្រួសារ និងមិត្តភក្តិ) និងដោយកិច្ចបំរើ HACC ផ្សេងទៀត ។

HACC អាចផ្តល់កិច្ចបំរើជំនួយចាំបាច់ដើម្បីអោយមនុស្សវ័យចាស់ទន់ខ្សោយ និងមនុស្សមានពិការភាពអាចបន្តរស់នៅក្នុង សហគមន៍របស់គេបាន ។ កិច្ចបំរើទាំងនេះផ្តល់ជូនអ្នកដែលមានសិទ្ធិទទួលនូវជំនួយនៅផ្ទះ ការជួយអោយទៅចូលរួមក្នុងសហគន៍ និង ការឈប់សំរាកសំរាប់អ្នកមើលថែ ។

កិច្ចបំរើ HACC ត្រូវបានគេផ្តល់ជូននៅផ្ទះ ឬសហគមន៍ក្នុងមូលដ្ឋាន ហើយអាចផ្តល់ជូនដោយភ្នាក់ងារ HACC មជ្ឈមណ្ឌលសុខភាព សហគមន៍ ឬសាលាក្រុង ។

## តើកិច្ចបំរើ HACC មានអ្វីខ្លះ?

### កិច្ចបំរើ HACC ដែលផ្តល់នៅក្នុងសហគមន៍រួមមាន៖

- **ការឈប់សំរាកពេលថ្ងៃនៅមជ្ឈមណ្ឌល** (centre-based day respite)
  ការថែទាំដែលសមស្របតាមវប្បធម៌របស់អតិថិជន សកម្មភាពជាក្រុមនៅមជ្ឈមណ្ឌល និងតំណើរកំសាន្តខ្លីៗពីមជ្ឈមណ្ឌល
- **យានដឹកជញ្ជូន** (transport)
  ជួយអតិថិជនចេញទៅក្រៅ និងទៅចូលរួមមជ្ឈមណ្ឌលសំរាកពេលថ្ងៃ ឡើងផ្សារ ឬទៅតាមការណាត់ជួប
- **ជំនួយផ្នែកសង្គម** (social support)
  ជួយអតិថិជនដោយជូនគេទៅផ្សារ ធានាគារ ឬទៅតាមការណាត់ជួប ឬសូម្បីតែនៅជាមួយអោយបានជាគ្នាគ្រាន់ជជែកលេង

### កិច្ចបំរើ HACC ដែលផ្តល់នៅផ្ទះរួមមាន៖

- **ជំនួយក្នុងផ្ទះ (ជួយក្នុងផ្ទះ/ជួយមើលផ្ទះ)** (domestic assistance)
  កិច្ចការផ្ទះដូចជា ជូតសំអាត បោកអ៊ុតខោអាវ
- **ការថែទាំផ្ទាល់ខ្លួន** (personal care)
  រួមមានការជួយងូតទឹក ស្លៀកពាក់ កាត់សក់ និងការប្រើបង្គន
- **ការថែទាំផ្ទះ** (home maintenance)
  ការថែទាំ គឺជាការជួសជុលផ្ទះទូទៅ ឬទីធ្លាផ្ទះរបស់អតិថិជន (ឧ. ការប្តូរអំពូលភ្លើង ការជួសជុលសោទ្វារ)
- **ការកែតម្រូវផ្ទះ** (home modification)
  កិច្ចបំរើអាចតំឡើងឧបករណ៍ជំនួយសុវត្ថិភាពដូចជា អាឡាម ជម្រាល និងបង្កាន់ដៃតោងនៅផ្ទះរបស់លោកអ្នក
- **ការថែទាំសហគមន៍** (community nursing)
  មានផ្តល់គិលានុបដ្ឋាកដែលមានចំណេះវិជ្ជាត្រឹមត្រូវមកមើលលោកអ្នកដល់ផ្ទះ (ដូចជា រុំរបួស ការផ្តល់ឱវាទលើបញ្ហាភាកនោម ឬភាកលាមកបត់ជើងមិនចេញ) ។

## កិច្ចបំរើ HACC មួយចំនួនអាចផ្តល់ជូននៅមជ្ឈមណ្ឌលសហគមន៍ ឬនៅផ្ទះរបស់លោកអ្នក៖

- **កិច្ចបំរើផ្នែកអាហារ** (food services)
  ប្រសិនបើលោកអ្នកមានការលំបាកក្នុងការចំអិនចំណីអាហារដោយខ្លួនឯង កិច្ចបំរើទាំងនេះអាចរួមមាន៖
  - ផ្តល់អាហារនៅមជ្ឈមណ្ឌលសហគមន៍ ឬនៅមជ្ឈមណ្ឌលសំរាកពេលថ្ងៃ
  - ជួយឡើងផ្សារទិញម្ហូប ធ្វើម្ហូប និងទុកដាក់វា
  - យកម្ហូបទៅដល់ផ្ទះ



- **កិច្ចបំរើអាឡាយហេល** (allied health services)
ចំពោះជនដែលមានបញ្ហាបាទជើង និងការនិយាយ
ឬត្រូវការជំនួយលើបញ្ហាដែលមានជាប្រចាំដែលបណ្តាលមកពីគ្រោះថ្នាក់ ឬជំងឺ។
កិច្ចបំរើរួមមាន ការព្យាបាលដោយហាត់ប្រាណ (ការហាត់ប្រាណ) ការព្យាបាលាទជើង (ការមើលថែបាទជើង) ការជួយអោយចេះនិយាយ (speech pathology)
ការជួយអោយធ្វើការខ្លួនឯងបាន (ឧបករណ៍ជំនួយនៅផ្ទះ)
និងឱវាទពីអ្នកឯកទេសខាងចំណីអាហារ (ការបរិភោគអាហារដែលល្អសំរាប់សុខភាព)។

- **កិច្ចបំរើជំនួយសំរាប់អ្នកមើលថែ** (support services for carers)
**តើអ្នកមើលថែជាអ្នកណា?** អ្នកមើថែគឺជាអ្នកថែទាំជនដែលមានពិការភាព ជំងឺផ្លែកខួរក្បាល ជំងឺរុំរ៉ៃ (មិនទាន់ជា) ឬជនវ័យចាស់ និងទន់ខ្សោយ ហើយមិនអាចមើលថែខ្លួនគេបាន។ អ្នកមើលថែអាចជា ប្តី/ប្រពន្ធ ដៃគូ សមាជិកគ្រួសារ អ្នកជិតខាង ឬមិត្តភក្តិ។

  ការមើលថែជនវ័យចាស់ទន់ខ្សោយ
ឬជនដែលមានពិការភាពអាចជាការងារមួយដែលពិបាកយ៉ាងខ្លាំង ហើយអ្នកមើលថែអាចត្រូវការការឈប់សំរាក ឱវាទ និងជំនួយដើម្បីជួយគេទប់ទល់នឹងតួនាទីថែទាំរបស់គេ។
ប្រសិនបើលោកអ្នកជាអ្នកមើលថែ លោកអ្នកអាចសុំជំនួយតាមរយះ HACC
និងកិច្ចបំរើផ្សេងទៀតដូចជា:

- **ការសំរាកពីការមើលថែ** (respite care)
កិច្ចបំរើនេះផ្តល់អ្នកមើលថែនូវការឈប់សំរាកពីការមើលថែ ក្នុងខណៈ
ដែលបុគ្គលិករបស់គេផ្តល់ការមើលថែដល់ជនត្រូវការការមើលថែជំនួស។
អ្នកដែលត្រូវគេមើលថែអាចទទួលការមើលថែ នៅផ្ទះរបស់ខ្លួន
ឬនៅមជ្ឈមណ្ឌលសំរាកពេលថ្ងៃ។ ក្នុងករណីភាគច្រើន
គេធ្វើផែនការសំរាប់ការឈប់សំរាកពីការមើលថែ ទុកជាមុន
ប៉ុន្តែគេអាចផ្តល់វាអោយបានក្នុងករណីបន្ទាន់។

- **ជំនួយ និងពតិមាន** (support and information)
កិច្ចបំរើនេះជួយអ្នកមើលថែរកការឈប់សំរាករយ:ពេលវែង
ដូចជាកន្លែងស្នាក់នៅបណ្តោះអាសន្ននៅ នីស៊ីងហូម (nursing home)
កន្លែងមនុស្សចាស់នៅ (aged people's hostel) ឬនៅមន្ទីរពេទ្យមូលដ្ឋាន
ក្នុងតំបន់មួយចំនួន។ កិច្ចបំរើនេះអាចជួយរកកន្លែងសំរាកដែលសមរម្យបំផុត
សំរាប់ជនដែលត្រូវការការថែទាំ។
ការធ្វើដូច្នេះអនុញ្ញាតអោយអ្នកមើលថែឈប់សំរាកបានយូរពីតួនាទីមើលថែរបស់គេ។

- **កិច្ចបំរើជំនួយផ្សេងទៀតសំរាប់អ្នកមើលថែ:**
**Carers Queensland** (ឃែរ៉័ ខ្វីនស្លែន)
មានផ្តល់ក្រុមគាំទ្រអ្នកមើលថែ
ការពិគ្រោះផ្តល់ឱវាទដល់ អ្នកមើលថែ
ឯកសារដោយឥតគិតប្រាក់
ការបណ្តុះបណ្តាល និងពតិមាន។
1800 242 636**
(ទូរសព្ទ័ដោយគិតថ្លៃក្នុងម៉ោងធ្វើការ)



- **Carers' Kit:**
**(សំណុំពតិមានសំរាប់អ្នកមើលថែ)**
សំណុំពតិមានផ្តល់ឱវាទស្តីពីការមើលថែ
នៅផ្ទះអាចរក
បានដោយមិនអស់ប្រាក់ពីមជ្ឈមណ្ឌលធនធានសំរាប់អ្នកមើលថ
សហពន្ធ័ (Commonwealth Carer Resource Centre)
Call 1800 242 636** (Freecall™ business hours)

- **Commonwealth Carer Respite Centres:**
**(មជ្ឈមណ្ឌលឈប់សំរាកសំរាប់អ្នកមើលថែសហពន)**
Call 1800 059 059** (Freecall™ 24 hours)

- **កិច្ចបំរើជំនួយអ្នកមើលថែផ្សេងទៀត:**
មានកិច្ចបំរើជំនួយអ្នកមើលថែផ្សេងទៀតដែលអាចជួយលោកអ្នកបាន។
សូមទាក់ទងអ្នកសម្របសម្រួល HACC
ក្នុងមូលដ្ឋានរបស់លោកអ្នកដើម្បីសួររកពតិមានទំនាក់ទំនង។
**ជំនួយជាប្រាក់** អាចផ្តល់ជូនអ្នកមើលថែជាប្រាក់ឧបត្ថម្ភបន្ថែមសំរាប់អ្នកមើលថែ
(Carer Allowance) និង ប្រាក់ជំនួយសំរាប់អ្នកមើលថែ (Carer Payment) ។
សូមទាក់ទងសិនធ័រលីងតាមលេខ 13 2717 ។

## តើអ្នកណាមានសិទ្ធិទទួលកិច្ចបំរើ HACC?

កិច្ចបំរើ HACC ៖ាជជគឺសំរាប់ជនដែលត្រូវការជំនួយដើម្បីបន្តរស់នៅផ្ទះក្នុងសហគមន៍ ពីព្រោះ:

- គេជាជនវ័យចាស់ទាន់ខ្សោយដែលមានការពិបាកក្នុងការបំពេញការងារប្រចាំថ្ងៃ ដូចជា ងូតទឹក ស្លៀកពាក់ ឬធ្វើការងារផ្ទះ។

ឬ

- គជាជនវ័យក្មេងដែលមានក៏រិតពិការភាពពីមធ្យម ដល់ខ្លាំង

ហើយ

- គេប្រឈមមុខនឹងការត្រូវចូលទៅនៅ នីស៊ីងហូម ឬហូស្តែលសំរាប់មនុស្សចាស់

  កិច្ចបំរើ HACC ក៏អាចផ្តល់ជូនអ្នកដែលមើលថែជនវ័យចាស់ទន់ខ្សោយ ឬអ្នកដែលមានពិការភាព។



## តើខ្ញុំទទួលបានកិច្ចបំរើ HACC ដោយរបៀបណា?

លោកអ្នកដោយផ្ទាល់ វេជ្ជបណ្ឌិត ឬមន្ទីរពេទ្យរបស់លោកអ្នក សមាជិកគ្រួសារ ឬមិត្តភក្តិអាចទាក់ទង:

- ខំម៉ន់វែល ឃែលីង សិនធ័រ (Commonwealth Carelink Centre) ដើម្បីពិភាក្សាសេចក្តីត្រូវការរបស់លោកអ្នក ឬ
- អ្នកសម្របសម្រួល HACC ក្នុងមូលដ្ឋានរបស់លោកអ្នកដើម្បីធ្វើការវាយតម្លៃលើសេចក្តីត្រូវការរបស់លោកអ្នក ។ ចំពោះពតិមានទំនាក់ទំនង សូមអានទំព័រខាងក្រោយ ។

## ការវាយតម្លៃ

ដើម្បីវាយតម្លៃសេចក្តីត្រូវការរបស់លោកអ្នក បុគ្គលិកមកពីភ្នាក់ងារ HACC ពិភាក្សាជាមួយលោកអ្នកដើម្បីដឹងថាតើលោកអ្នក លៃលកដោះស្រាយការរស់នៅប្រចាំថ្ងៃរបស់លោកអ្នកយ៉ាងដូចម្តេច ។ ពតិមានដែលលោកអ្នកផ្តល់ជូននឹងត្រូវគេសរសេរចូលក្នុង ក្រដាស់កំណត់សេចក្តីត្រូវការជាប្រចាំរបស់ HACC (HACC Ongoing Needs Identification – ONI) ។ ពតិមាននេះ ត្រូវបានប្រើដោយភ្នាក់ងារ HACC ដើម្បីសម្រេចថាតើលោកអ្នក មានសិទ្ធិទទួលកិច្ចបំរើទេ និងថាតើកិច្ចបំរើប្រភេទណាដែលលោកអ្នក ត្រូវការដើម្បីជួយលោកអ្នកបន្តរស់នៅផ្ទះតទៅទៀត ។

## តើខ្ញុំត្រូវបង់ប្រាក់សំរាប់កិច្ចបំរើ HACC ទេ?

កិច្ចបំរើ HACC នីមួយៗមានគោលនយោបាយថ្លៃឈ្នួលរបស់ខ្លួន ក៏ប៉ុន្តែកិច្ចបំរើភាគច្រើនសុំលោកអ្នកអោយបង់ប្រាក់វិភាគទាន តិចតួចប៉ុណ្ណោះ អាស្រ័យទៅលើស្ថានភាពរបស់លោកអ្នក ។

ការយោគយល់ជាពិសេសនឹងត្រូវផ្តល់ជូនជនដែលមានការខ្វះខាតផ្នែកថវិការ ។





## ត្រូវការពតិមានបន្ថែមទៀត?

ចំពោះពតិមានបន្ថែមទៀតស្តីពីកិច្ចបំរើ HACC នៅក្នុងតំបន់របស់លោកអ្នក សូមទាក់ទង:

**COMMONWEALTH CARELINK CENTRE*** (ខំម៉ន់វែល ឃែលីង សិនធ័រ)**: 1800 052 222**** (ទូរសព្ទ័ដោយគិតថ្លៃក្នុងម៉ោងធ្វើការ)

---

**វេជ្ជបណ្ឌិតរបស់លោកអ្នក:** វេជ្ជបណ្ឌិតរបស់លោកអ្នកអាចធ្វើការជាមួយកិច្ចបំរើផ្សេងទៀតដើម្បីជួយលោកអ្នកសុំការថែទាំដែល លោកអ្នកត្រូវការ ។

---

ឬ ទូរសព្ទ័ភ្នាក់ងារ **HACC** នៅក្នុងមូលដ្ឋានរបស់លោកអ្នក

ឬអានវិបសៃ

**www.health.qld.gov.au/hacc**

---

* ផ្តល់ពតិមានដោយឥតគិតថ្លៃអំពីការថែទាំជនវ័យចាស់ក្នុងសហគមន៏ ពិការភាព និងកិច្ចបំរើគាំទ្រផ្សេងទៀត ។

** ការទូរសព្ទ័ពីទូរសព្ទ័ដៃនឹងត្រូវគេគិតថ្លៃតាមតម្លៃដែលប្រពន្ធ័ទូរសព្ទ័កំណត់ ។

hacc
*home and community care*
A JOINT COMMONWEALTH AND STATE/TERRITORY PROGRAM
PROVIDING FUNDING AND ASSISTANCE FOR AUSTRALIANS IN NEED

កម្មវិធីកិច្ចបំរើថែទាំនៅតាមផ្ទះនិងក្នុងសហគមន៏ទទួលការឧបត្ថម្ភថវិការរួមពីរដ្ឋភិបាលសហព័ន្ធ និងរដ្ឋាភិបាលឃ្វីនស្លែន

hacc
home and community care
A JOINT COMMONWEALTH AND STATE/TERRITORY PROGRAM
PROVIDING FUNDING AND ASSISTANCE FOR AUSTRALIANS IN NEED

# ឯកសារពតិមានពីកិច្ចបំរើ HACC ជាភាសាផ្សេងៗ

សន្លឹកពតិមាន/កូនសៀវភៅនៅលើវិបសៃទាំងពីររបស់កម្មវិធី ខាជជ រដ្ឋឃ្វីនស្លែន (គឺ កិច្ចបំរើរបស់ ខាជជ និងសិទ្ធិរបស់លោកអ្នក) អាចរកបានជាភាសាខាងក្រោម៖

- Arabic
- Bosnian/Croatian
- Chinese
- Dutch
- Finnish
- French
- German
- Greek
- Hindi
- Hmong
- Hungarian
- Italian
- Japanese
- Khmer
- Korean
- Polish
- Samoan
- Serbian
- Spanish
- Tagalog
- Vietnamese

បញ្ជីសន្លឹកពតិមាន/កូនសៀវភៅនៅលើវិបសៃ និងសេចក្តីបកប្រែអាចចំលងបានពីវិបសៃ HACC:

**www.health.qld.gov.au/hacc/multicultural.asp**

ឯកសារទាំងនេះមានជា CD-ROM ហើយអាចរកបាន ដោយមិនគិតថ្លៃពី៖

**HACC_Resource@health.qld.gov.au**

បណ្ណ័ប្រកាសពហុវប្បធម៌ HACC (ទំហំ A2 បត់ជា A4) អាចរកបានពី Resource Unit ។

*Fact sheets*




*CD*

*A2 Poster*

hacc
home and community care
A JOINT COMMONWEALTH AND STATE/TERRITORY PROGRAM
PROVIDING FUNDING AND ASSISTANCE FOR AUSTRALIANS IN NEED

Aradia Multilingual Communications - 3737